សួស្តី នៅក្នុងរូបភាពនេះ យើងនឹងនិយាយអំពីការកើតជំងឺផ្តាសាយ បាទ អញ្ចឹងការកើតជំងឺផ្តាសាយ
គឺជាជំងឺមួយ ដែលតែងតែឆ្លងមកមនុស្សតាមរយៈវីរុស ហើយវីរុសរបស់ជំងឺផ្តាសាយ
គឺតែងតែកើតមានឡើងនៅក្នុងរដូវត្រជាក់ ឬក៏រដូវរងា ហើយនិងរដូវភ្លៀង
អញ្ចឹងពេលណាដែលរដូវភ្លៀង នៅពេលដែលយើងត្រូវទឹកភ្លៀង ឬក៏នៅពេលដែលយើងត្រូវទឹក
ឬត្រូវអាកាសធាតុត្រជាក់យូរ វាអាចនឹងធ្វើឲ្យយើងកើតផ្តាសាយ
ដូចជានៅពេលដែលយើងឈរនៅខាងក្រៅពេលយប់ជ្រៅ
នៅពេលយប់ជ្រៅតែងតែមានខ្យល់ត្រជាក់ អញ្ចឹងប្រសិនបើយើងឈរនៅខាងក្រៅផ្ទះ
ឬក៏ខាងក្រៅបន្ទប់ពេលយប់ជ្រៅយូរ អញ្ចឹងវាអាចនឹងធ្វើឲ្យយើងផ្តាសាយបាន
ដោយសារតែយើងត្រូវនឹងខ្យល់ត្រជាក់នូវអាកាសធាតុនៅខាងក្រៅ ឬក៏មួយទៀត
ប្រសិនបើយើងនៅហាលភ្លៀង ក៏អាចធ្វើឲ្យយើងមានជំងឺផ្តាសាយបានដែរ
ព្រោះថាវីរុសទាំងអស់នេះ គឺតែងតែចម្លងមកមនុស្ស នៅពេលដែលមនុស្សនៅក្រោមទឹកភ្លៀង
ឬក៏នៅកន្លែងដែលមានអាកាសធាតុត្រជាក់។

អញ្ចឹងយើងមកមើលរូបភាពទាំងអស់គ្នា ដែលនៅក្នុងរូបភាពទី ១ យើងឃើញមានក្មេងប្រុសម្នាក់
បាទ ក្មេងប្រុសនោះ គាត់មានអាយុប្រហែលជា ១៨ ឆ្នាំ អញ្ចឹងគាត់កំពុងតែរត់កាត់ភ្លៀង
ដែលយើងឃើញក្មេងប្រុសនោះ គាត់ពាក់អាវពណ៌លឿង ពាក់អាវយឺតពណ៌លឿង
អាវយឺតរបស់គាត់គឺមានកមូល ហើយអាវយឺតរបស់គាត់គឺដៃខ្លី
អញ្ចឹងគាត់ពាក់អាវយឺតពណ៌លឿងដៃខ្លី ខោជើងវែងពណ៌ស
ហើយគាត់មានពាក់ស្បែកជើងប៉ាតាផងដែរ យើងឃើញក្មេងប្រុសម្នាក់នោះ
គាត់កំពុងតែរត់កាត់ភ្លៀង អញ្ចឹងបានន័យថានៅក្នុងរូបភាពទី ១ នេះ
គឺកំពុងតែមានភ្លៀងធ្លាក់យ៉ាងខ្លាំង ដែលភ្លៀងនោះ គឺយើងឃើញមាន
ជាធម្មតាភ្លៀងគឺតែងតែកើតឡើងនៅពេលដែលមានពពកខ្មៅច្រើន
អញ្ចឹងបានន័យថានៅក្នុងរូបភាពនេះ គឺភ្លៀងធ្លាក់មក ដោយសារមានពពកខ្មៅច្រើន
ហើយភ្លៀងគឺតែងតែមានលាយឡំនឹងខ្យល់ ព្រោះថានៅពេលដែលយើង
យើងឃើញភ្លៀងនៅក្នុងរូបភាពនេះ គឺភ្លៀងកំពុងតែទ្រេត អញ្ចឹងបានន័យថាតំណក់ទឹកភ្លៀងគឺទ្រេត
បានន័យថាកំពុងតែមានខ្យល់ អញ្ចឹងខ្យល់អាចធ្វើឲ្យទឹកភ្លៀងផ្លាស់ប្តូរទិសដៅ
បានន័យថាភ្លៀងធ្លាក់ពីលើចុះក្រោម ក៏ប៉ុន្តែប្រសិនបើមានខ្យល់ខ្លាំង ប្រសិនបើភ្លៀងនោះ
លាយឡំនឹងខ្យល់ នោះវាធ្វើឲ្យខ្យល់ វាធ្វើឲ្យភ្លៀងផ្លាស់ប្តូរទិសដៅរបស់វា
បានន័យថាវាមិនធ្លាក់ចុះក្រោមពីលើមកក្រោមតែម្តងទេ គឺវាតែងតែធ្លាក់ពីឆ្វេងទៅស្តាំ
ឬក៏ពីស្តាំមកឆ្វេងតាមទិសដៅនៃខ្យល់ អញ្ចឹងភ្លៀងតែងតែផ្លាស់ប្តូរទិសដៅតាមកម្លាំងនៃខ្យល់
អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញថា ក្មេងប្រុសម្នាក់កំពុងតែរត់កាត់ភ្លៀង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងយើងឃើញដៃទាំងពីររបស់គាត់ លើកឡើងលើ កាន់សៀវភៅមួយ
បានន័យថាគាត់កាន់សៀវភៅដើម្បីយកទៅបាំងភ្លៀង អញ្ចឹងគាត់អត់មានអាវភ្លៀងទេ
អញ្ចឹងក្មេងប្រុសម្នាក់នេះ គាត់អត់មានអាវភ្លៀង ហើយក៏អត់មានឆត្រដែរ
ដែលអាវភ្លៀងគឺជាអាវមួយប្រភេទដែលធ្វើអំពីកៅស៊ូ ឬក៏ធ្វើអំពីប្លាស្ទិក អញ្ចឹងនៅពេលដែលភ្លៀង
យើងអាចពាក់អាវភ្លៀងបាន យើងពាក់អាវភ្លៀងពីលើខ្លួនយើង ដើម្បីកុំឲ្យវាទទឹកសម្លៀកបំពាក់
ឬក៏ឯកសណ្ឋានរបស់យើង អញ្ចឹងប្រសិនបើយើងអត់មានអាវភ្លៀងទេ យើងអាចប្រើឆត្រ
ឆត្រក៏អាចយើងយកមកបាំងភ្លៀងបានដែរ ប៉ុន្តែនៅក្នុងរូបភាពនេះគឺក្មេងប្រុសនោះ
គាត់អត់មានអាវភ្លៀង ហើយក៏អត់មានឆត្រដែរ បានន័យថាប្រហែលជាគាត់ភ្លេចនៅផ្ទះ
ឬក៏ដោយសារតែរដូវនោះមិនមែនជារដូវភ្លៀង ក៏ប៉ុន្តែវាជាភ្លៀងកក់ខែ អញ្ចឹងនៅក្នុងរូបភាពនេះ
បានន័យថាក្មេងប្រុសនោះ គាត់ភ្លេចយកអាវភ្លៀង ឬក៏ភ្លេចយកឆត្រពីផ្ទះទៅ
ដូច្នេះហើយគាត់អត់មានឆត្រទេនៅពេលដែលភ្លៀង អញ្ចឹងគាត់ក៏បានយកសៀវភៅរបស់គាត់
ដើម្បីបាំងភ្លៀង កុំឲ្យទទឹកក្បាលរបស់គាត់ ព្រោះថានៅពេលដែលភ្លៀងទទឹកក្បាលច្រើន
អាចធ្វើឲ្យយើងមានជំងឺផ្តាសាយបាន។

បន្ទាប់មកទៀតនៅក្នុងរូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញថា បន្ទាប់ពីរត់មួយសន្ទុះមក
ក្មេងប្រុសនោះក៏បានទៅដល់ចំណតស្ថានីយរថយន្តក្រុង ឬក៏ចំណតឡានក្រុង ហើយយើងឃើញថា
ក្មេងប្រុសនេះក៏បានចូលទៅក្នុងឡានក្រុង ឬក៏ចូលទៅក្នុងរថយន្តក្រុងនោះ
ដើម្បីបន្តដំណើរទៅផ្ទះរបស់គេ អញ្ចឹងយើងឃើញនៅក្នុងរថយន្តក្រុងនោះ គឺមានមនុស្សជាច្រើន
មានមនុស្សប្រុស មានមនុស្សស្រីជាច្រើន ដែលនៅក្នុងរូបភាពនេះ គឺមានអ្នកខ្លះអង្គុយ
និងមានអ្នកខ្លះឈរ ដោយសារតែនៅក្នុងឡានក្រុង គឺយើងឃើញថាមានកៅអីច្រើន
គឺកៅអីគេអាចរៀបចំជាពីរជួរ ឬក៏បួនជួរ សម្រាប់មនុស្សអង្គុយ
ហើយនៅមានចន្លោះកណ្តាលមួយទៀតសម្រាប់មនុស្សឈរ ក៏ប៉ុន្តែដោយសារតែមានភ្ញៀវច្រើនពេក
ដោយសារតែមានភ្ញៀវជិះ ជិះរថយន្តក្រុងច្រើនពេក ដូច្នេះហើយទើបធ្វើឲ្យមានអ្នកខ្លះឈរ
អ្នកខ្លះអង្គុយ អ្នកណាដែលឡើងមកដល់រថយន្តក្រុងមុន ឬក៏ឡើងមកដល់ឡានក្រុងមុន គេអង្គុយ
ចំណែកឯអ្នកឡើងមកក្រោយ គឺគេឈរ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញមាននារីម្នាក់
គាត់កំពុងតែអង្គុយលើកៅអីឡានក្រុងក្បែរបង្អួច អញ្ចឹងជាទូទៅឡានក្រុងតែងតែមានបង្អួច
ហើយនៅខាងក្រោយនារីនោះ គឺមានបុរសម្នាក់ទៀត ដែលកំពុងតែអង្គុយដែរ ហើយយើងឃើញថា
ក្មេងប្រុសដែលពាក់អាវលឿងនោះ គាត់កំពុងតែឈរ ដោយសារតែគាត់ឡើងឡានក្រុងយឺតជាងគេ
ដូច្នេះហើយគាត់ក៏ត្រូវតែឈរ ដោយឈរតោងរបារដែកមួយ អញ្ចឹងនៅក្នុងឡានក្រុង
នៅពេលដែលអ្នកឈរ គេឲ្យតោងរបារដែកមួយ គឺគេមានរបារដែក ដើម្បីឲ្យឈរតោង
ដើម្បីទប់លំនឹងខ្លួន ព្រោះថានៅពេលដែលឡានធ្វើដំណើរទៅមុខ គឺយើងអាចនឹងបាត់បង់លំនឹង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អាចធ្វើឲ្យយើងដួល ឬមានគ្រោះថ្នាក់បាន ដូច្នេះយើងត្រូវតែតោងរបារដែកនៅក្នុងឡានក្រុង
ដើម្បីទប់លំនឹង ដែលយើងឃើញនៅទល់មុខក្មេងប្រុសដែលពាក់អាវលឿងនោះ
យើងឃើញមានបុរសម្នាក់ទៀត គឺគាត់ពាក់អាវពណ៌ខៀវដៃខ្លីដូចគ្នា
ហើយគាត់កំពុងតែឈរតោងរបារដែកដូចគ្នា គឺឈរទល់មុខនឹងក្មេងប្រុសម្នាក់នោះ
ក៏ប៉ុន្តែបុរសម្នាក់នោះ គាត់កំពុងតែកណ្តាស់ បានន័យថាគាត់ផ្តាសាយ គាត់មានជំងឺផ្តាសាយ
ដូច្នេះគាត់ក៏កណ្តាស់ អញ្ចឹងជាទូទៅជំងឺផ្តាសាយ គឺអាចចម្លងទៅអ្នកដទៃផ្សេងទៀតបាន
ដោយសារតែតាមរយៈការកណ្តាស់ ឬក៏ការនៅជិតនឹងអ្នកមានជំងឺផ្តាសាយ
អញ្ចឹងនៅក្នុងរូបភាពនេះ បុរសដែលមានជំងឺផ្តាសាយនោះ គាត់អត់បានពាក់ម៉ាស
ឬក៏អត់បានការពារទេ អញ្ចឹងបានន័យថានៅពេលដែលគាត់កណ្តាស់
គឺគាត់កណ្តាស់នៅក្នុងឡានក្រុងទល់មុខក្មេងប្រុសម្នាក់នោះ អញ្ចឹងនៅក្នុងនេះយើងឃើញថា
បុរសម្នាក់នោះ គាត់បានយកដៃរបស់គាត់ដាក់នៅក្បែរមាត់ដើម្បីកណ្តាស់
បានន័យថាគាត់ខ្ទប់មាត់ដែរ ក៏ប៉ុន្តែជំងឺមេរោគផ្តាសាយនេះ គឺនៅពេលដែលយើងកណ្តាស់
គឺមេរោគនឹងចេញតាមទឹកមាត់ អញ្ចឹងបានន័យថា នៅពេលដែលយើងកណ្តាស់
វាអាចនឹងចូលមកក្នុងបរិយាកាស ហើយឆ្លងទៅអ្នកដទៃបាន អញ្ចឹងជំងឺផ្តាសាយគឺជាជំងឺឆ្លង
ដែលអាចចម្លងទៅអ្នកដទៃនៅពេលដែលយើងមិនប្រយ័ត្ន អញ្ចឹងបុរសម្នាក់នេះ
គាត់កំពុងតែកណ្តាស់នៅទល់មុខនឹងក្មេងប្រុសដែលពាក់អាវលឿង
អញ្ចឹងវាអាចធ្វើឲ្យក្មេងប្រុសដែលពាក់អាវលឿង ឆ្លងជំងឺផ្តាសាយពីបុរសនេះបាន។

បន្ទាប់មកទៀតចូលដល់រូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញថា
បន្ទាប់ពីជិះរថយន្តក្រុងមួយសន្ទុះក្រោយមក ក្មេងប្រុសម្នាក់នោះ
គាត់ក៏បានដើរមកដល់ផ្ទះរបស់គាត់ អញ្ចឹងគាត់ក៏បានចូលទៅក្នុងផ្ទះ គាត់បានចូលទៅក្នុងផ្ទះ
ដោយយើងឃើញខ្លួនរបស់គាត់គឺទទឹកជោក អញ្ចឹងខ្លួនរបស់គាត់គឺទទឹកទៅដោយទឹកភ្លៀង
ដោយសារតែគាត់អម្បាញ់មិញរត់កាត់ភ្លៀង ហើយគាត់ឡើងជិះឡានក្រុង
អញ្ចឹងនៅពេលដែលគាត់រត់កាត់ភ្លៀង ធ្វើឲ្យខោអាវរបស់គាត់ ឬក៏សម្លៀកបំពាក់របស់គាត់ទទឹក
យើងឃើញនៅក្នុងរូបភាពនេះ គឺគាត់កំពុងតែបើកទ្វារចូលផ្ទះ អញ្ចឹងយើងឃើញថា
មានទឹកនៅលើខ្លួនរបស់គាត់ ខ្លួនប្រាណរបស់គាត់ បានន័យថាគាត់កំពុងតែសើម ហើយគាត់ក៏បាន
ខោអាវរបស់គាត់គឺសើម ដែលយើងឃើញនៅខាងក្រៅទ្វារ យើងឃើញនៅខាងក្រៅ
គឺមេឃកំពុងតែភ្លៀង អញ្ចឹងបានន័យថាភ្លៀងអត់ទាន់រាំងទេ ភ្លៀងអត់ទាន់រាំងទេ
ប៉ុន្តែបុរសម្នាក់នោះ គាត់បានមកដល់ផ្ទះរួចហើយ
ហើយគាត់ក៏បានដើរចូលក្នុងផ្ទះរបស់គាត់ទាំងខ្លួនទទឹក។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតនៅក្នុងរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ គឺជាពេលយប់ អញ្ចឹងរូបភាពទី ៤ នៅខាងឆ្វេងដៃ គឺជាពេលយប់ អញ្ចឹងពេលយប់គឺយើងត្រូវគេង អញ្ចឹងបានន័យថាក្មេងប្រុសម្នាក់នោះ បន្ទាប់ពីគាត់មកដល់ផ្ទះ គឺនៅពេលយប់ អញ្ចឹងនៅពេលយប់គឺមានសភាពត្រជាក់ ដូច្នេះប្រសិនបើមានភ្លៀង គឺងាយនឹងធ្វើឲ្យយើងផ្ដាសាយណាស់ អញ្ចឹងប្រសិនបើយើងត្រូវទឹកភ្លៀងនៅពេលយប់ គឺអាចធ្វើឲ្យយើងផ្ដាសាយបានយ៉ាងងាយ ហើយក្មេងប្រុសម្នាក់នេះ គាត់ត្រូវទឹកភ្លៀងពេលយប់ ហើយឡើងជិះឡានក្រុងគឺគាត់ត្រូវមាន ត្រូវបានបុរសម្នាក់ គាត់កណ្ដាស់នៅលើឡានក្រុង ដែលធ្វើឲ្យទឹកមាត់របស់គាត់ខ្ទាតត្រូវនឹងក្មេងប្រុសម្នាក់នោះ អាចធ្វើឲ្យគាត់ឆ្លងជំងឺផ្ដាសាយបាន ឥឡូវនេះមកដល់ពេលយប់ នៅពេលដែលគាត់ដល់ផ្ទះនៅពេលយប់ ក្មេងប្រុសម្នាក់នោះ ក៏បានចូលគេង អញ្ចឹងគាត់បានដើរសំដៅទៅបន្ទប់គេងរបស់គាត់ អញ្ចឹងនៅក្នុងរូបភាពទី ៤ នេះ ក្មេងប្រុសម្នាក់នោះក៏បានដើរសំដៅទៅបន្ទប់គេងរបស់គាត់ ហើយឡើងគេងនៅលើគ្រែ អញ្ចឹងយើងឃើញនៅក្នុងបន្ទប់គេងរបស់គាត់ គឺមានគ្រែមួយ គឺមានគ្រែ ហើយនៅលើគ្រែនោះគឺមានខ្នើយ ដែលក្មេងប្រុសម្នាក់នោះ គាត់កំពុងតែកើយនៅលើខ្នើយ ហើយដណ្ដប់ភួយ បានន័យថាត្រជាក់ អាកាសធាតុនៅខាងក្រៅគឺត្រជាក់ អញ្ចឹងហើយគឺ គឺគាត់ត្រូវដណ្ដប់ភួយ ព្រោះថានៅពេលដែលត្រជាក់ គឺធ្វើឲ្យយើងមានអារម្មណ៍ថារងា អញ្ចឹងនៅពេលដែលយើងរងា យើងត្រូវដណ្ដប់ភួយ ដើម្បីឲ្យបាត់រងា ឬក៏ដើម្បីឲ្យមានភាពកក់ក្ដៅ អញ្ចឹងបុរសម្នាក់នោះ គ្រែគេងរបស់គាត់ គឺនៅជិតនឹងបង្អួចមួយ ដែលយើងឃើញបង្អួចនោះគឺចំហ ឬក៏ជាបង្អួចកញ្ចក់ អញ្ចឹងបានន័យថាមើល អាចមើលឃើញទៅខាងក្រៅបាន ក៏ប៉ុន្តែគាត់អត់បើកបង្អួចទេ អញ្ចឹងបានន័យថាបង្អួចរបស់គាត់គឺកញ្ចក់ថ្លា អាចមើលខាងក្រៅបាន ដោយមិនចាំបាច់បើកបង្អួច ដែលយើងឃើញនៅក្រៅបង្អួច គឺមានផ្ទះអ្នកជិតខាងរបស់គាត់ អញ្ចឹងអ្នកដែលនៅជិតផ្ទះគ្នា យើងហៅថាអ្នកជិតខាង អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញថា អ្នកជិតខាងរបស់គាត់ គឺនៅក្បែរគាត់ ហើយមានរូបភាពព្រះចន្ទមួយផងដែរ អញ្ចឹងពេលយប់គឺមានព្រះចន្ទ ពេលថ្ងៃគឺមានព្រះអាទិត្យ ដែលនៅក្នុងរូបភាពនេះ គឺគាត់កំពុងតែគេងលក់នៅពេលយប់ ចំណែកឯនៅក្នុងរូបភាពទី ៤ ដដែល ប៉ុន្តែនៅខាងស្ដាំ បានន័យថារូបភាពទី ៤ ដែលនៅខាងស្ដាំនេះ គឺបានន័យថាពេលព្រឹក អញ្ចឹងយើងឃើញនៅខាងក្រោយបង្អួច គឺមានព្រះអាទិត្យរះ អញ្ចឹងពេលយប់គឺមានព្រះចន្ទ ចំណែកឯព្រឹកឡើងគឺមានព្រះអាទិត្យរះ ដែលយើងឃើញនៅពេលនេះ គឺគាត់ភ្ញាក់ពីគេងហើយ អញ្ចឹងក្មេងប្រុសម្នាក់នោះ ឬក៏បុរសម្នាក់នោះ គាត់បានភ្ញាក់ពីគេង ដែលយើងឃើញគាត់ងើបក្បាលឡើងចេញពីខ្នើយ ក៏ប៉ុន្តែគាត់អត់ទាន់ងើបអង្គុយនោះទេ បានន័យថាគាត់គ្រាន់តែដឹងខ្លួន គាត់ឈប់គេងហើយ ក៏ប៉ុន្តែគាត់អត់ងើបអង្គុយនោះទេ គាត់គ្រាន់តែងើបក្បាលឡើងចេញពីខ្នើយ ដើម្បីមើលទៅថ្ងៃ ឬក៏មើលទៅនាឡិកាថាម៉ោងប៉ុន្មាន

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ឬក៏គាត់ចង់ដឹងថាពេលព្រឹកឬក៏ពេលថ្ងៃ ដូច្នេះគាត់គ្រាន់តែងើបក្បាលបន្តិចចេញពីខ្នើយតែប៉ុណ្ណោះ
ប៉ុន្តែគាត់អត់ទាន់ងើបអង្គុយចេញពីគ្រែគេងគាត់នៅឡើយទេ។

បន្ទាប់មកទៀតនៅក្នុងរូបភាពទី ៥ នៅក្នុងរូបភាពទី ៥ យើងឃើញថា ក្មេងប្រុសម្នាក់នោះ
គាត់ចាប់ផ្តើមឈឺក អញ្ចឹងបានន័យថាគាត់ចាប់ផ្តើមឈឺករបស់គាត់
ដែលបំពង់ករបស់គាត់គឺចាប់ផ្តើមឈឺ អញ្ចឹងធ្វើឲ្យគាត់ពិបាកក្នុងការនិយាយ
ពិបាកក្នុងការលេបទឹកមាត់ ហើយក៏ពិបាកក្នុងការញ៉ាំចំណីអាហារផងដែរ
ព្រោះថានៅពេលដែលយើងឈឺក យើងពិបាកនៅក្នុងការនិយាយខ្លាំងណាស់
ព្រោះនៅពេលដែលយើងនិយាយគឺត្រូវប្រើសំឡេងចេញពីបំពង់ក អញ្ចឹងប្រសិនបើយើងឈឺបំពង់ក
គឺយើងនឹងពិបាកក្នុងការបញ្ចេញសំឡេង ម្យ៉ាងវិញទៀតយើងពិបាកក្នុងលេបទឹកមាត់
ក៏ដូចជាញ៉ាំចំណីផ្សេងៗ ដោយសារតែនៅពេលដែលយើងញ៉ាំចំណី គឺយើងញ៉ាំតាមមាត់
ហើយនៅពេលដែលយើងលេបចំណីចូលទៅក្នុងពោះ គឺឆ្លងកាត់តាមបំពង់ក
អញ្ចឹងប្រសិនបើយើងឈឺក គឺវាធ្វើឲ្យយើងពិបាកក្នុងការលេបចំណីចូលទៅក្នុងពោះ
អញ្ចឹងឈឺកគឺជារោគសញ្ញាមួយ ដែលចាប់ផ្តើមនូវជំងឺផ្តាសាយ អញ្ចឹងប្រសិនបើយើងឈឺក
បានន័យថាយើងជិតកើតជំងឺផ្តាសាយហើយ ដូច្នេះយើងគួរតែប្រុងប្រយ័ត្ន យើងគួរតែមានការញ៉ាំថ្នាំ
ឬក៏ទៅជួបជាមួយនឹងគ្រូពេទ្យ ដើម្បីពិភាក្សា ដើម្បីកុំឲ្យកើតជំងឺផ្តាសាយបាន
ជាក់ស្តែងនៅក្នុងរូបភាពនេះ ក្មេងប្រុសម្នាក់នោះ គាត់ក៏ចាប់ផ្តើមឈឺក
ដោយយើងឃើញគាត់កំពុងតែយកដៃទៅខ្ទប់ករបស់គាត់ បានន័យថាគាត់ឈឺកខ្លាំង
ហើយយើងឃើញមុខគាត់ធ្វើមុខជូរ គាត់ធ្វើមុខជូរ បានន័យថាគាត់ឈឺ
អញ្ចឹងនៅពេលដែលយើងឈឺ យើងធ្វើមុខជូរ។

បន្ទាប់មកទៀតរូបភាពទី ៥ ដដែល រូបភាពទី ៥ ដដែល ប៉ុន្តែនៅកណ្តាល រូបភាពកណ្តាល
ដែលរូបភាពទី ៥ គឺមាន ៣ គឺខាងឆ្វេង កណ្តាល និងខាងស្តាំ អញ្ចឹងនៅក្នុងរូបភាពទី ៥ ប៉ុន្តែ
ចំណុចកណ្តាល គឺយើង ក្មេងប្រុសម្នាក់នោះ គាត់ក៏ចាប់ផ្តើមកណ្តាស់
អញ្ចឹងនៅពេលដែលយើងមានជំងឺផ្តាសាយ គឺយើងនឹងកណ្តាស់
បានន័យថាយើងកណ្តាស់ជាញឹកញាប់ បានន័យថាជាញឹកញាប់យើងតែងតែកណ្តាស់
ព្រោះថាយើងមានជំងឺផ្តាសាយ ដោយសារតែយើងរមាស់ចុងច្រមុះ
អញ្ចឹងនៅពេលដែលយើងរមាស់ចុងច្រមុះ វាអាចធ្វើឲ្យយើងកណ្តាស់ ហើយកណ្តាស់
យើងអាចធ្វើឲ្យខ្ទាតទឹកមាត់ ឬក៏អាចធ្វើឲ្យយើងខ្ទាតទឹកមាត់ចេញមកក្រៅ
ដែលទឹកមាត់របស់យើងនោះ ផ្ទុកនូវវីរុសផងដែរ អញ្ចឹងប្រសិនបើយើងអត់ការពារទេ
នៅពេលដែលទឹកមាត់របស់យើងខ្ទាតទៅប៉ះអ្នកដទៃ វាអាចធ្វើឲ្យអ្នកដទៃឆ្លងជំងឺផ្តាសាយពីយើង

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ព្រោះជំងឺផ្ដាសាយគឺឆ្លងតាមរយៈបរិយាកាស បានន័យថាឆ្លងតាមរយៈដង្ហើម
អញ្ចឹងប្រសិនបើយើងអត់ការពារ ឬយើងអត់ពាក់ម៉ាស គឺអាចធ្វើឲ្យយើងកណ្ដាស់
ហើយចម្លងទៅអ្នកដទៃបាន ជាក់ស្ដែងក្មេងប្រុសម្នាក់នេះ គឺគាត់បានឆ្លងពីបុរសម្នាក់
ដែលកណ្ដាស់នៅលើឡានក្រុង ដែលគាត់អត់បានការពារ អត់បានពាក់ម៉ាស
អញ្ចឹងធ្វើឲ្យក្មេងប្រុសម្នាក់នេះ គាត់ឆ្លងផ្ដាសាយដែរ ហើយគាត់កណ្ដាស់ដូចគ្នា។

បន្ទាប់មកទៀតរូបភាពនៅខាងស្ដាំដៃ រូបភាពទី ៥ នៅខាងស្ដាំដៃ គឺយើងឃើញថា
បន្ទាប់ពីកណ្ដាស់ហើយ ក្មេងប្រុសម្នាក់នោះ គាត់ក៏ចាប់ផ្ដើមហៀរសំបោរទៀត
អញ្ចឹងគាត់ហៀរសំបោរ ជាទូទៅជំងឺផ្ដាសាយធ្វើឲ្យយើងកណ្ដាស់
ធ្វើឲ្យយើងហៀរសំបោរជាញឹកញាប់ ធ្វើឲ្យយើងពិបាកដកដង្ហើម
អញ្ចឹងបានន័យថានៅពេលដែលយើងហៀរសំបោរ សំបោរគឺជាទឹកមួយខាប់ៗ
ដែលខាប់ចេញពីច្រមុះរបស់យើង នៅពេលដែលយើងមានជំងឺផ្ដាសាយ
អញ្ចឹងនៅពេលដែលយើងមានជំងឺផ្ដាសាយ យើងនឹងមានហូរទឹកខាប់ៗចេញពីច្រមុះរបស់យើង
ដែលយើងហៅថាសំបោរ អញ្ចឹងនៅក្នុងរូបភាពនេះ បុរសម្នាក់នោះ គាត់កំពុងតែញើសសំបោរ
បានន័យថានៅពេលដែលវាហៀរសំបោរ យើងត្រូវញើសវាចេញ ឲ្យស្អាតច្រមុះ
ព្រោះថានៅពេលដែលវាហៀរសំបោរ គឺវាប្រឡាក់ច្រមុះរបស់យើង ដូច្នេះហើយយើងត្រូវញើសវា
ហើយជូតវាឲ្យស្អាត ដោយយើងប្រើប្រាស់កន្សែង ឬក៏ក្រដាសជូតមាត់
ដើម្បីជូតសម្អាតច្រមុះរបស់យើង អញ្ចឹងយើងត្រូវតែសម្អាតច្រមុះរបស់យើងជាប្រចាំ
នៅពេលដែលយើងមានជំងឺផ្ដាសាយ ដែលជាក់ស្ដែងយើងឃើញក្មេងប្រុសម្នាក់នេះ
គាត់បានយកក្រណាត់មួយ យកក្រណាត់មកខ្ទប់ច្រមុះរបស់គាត់ ដើម្បីញើសសំបោរចេញ
អញ្ចឹងយើងឃើញមានទឹកខ្ទាតចេញពីច្រមុះរបស់គាត់ធ្លាក់ចុះទៅក្រោម
ដែលយើងឃើញថានេះគាត់កំពុងតែញើសសំបោរចេញ
ដែលញើសយកទឹកខាប់ៗចេញពីច្រមុះរបស់គាត់ ហើយសំបោរនេះគឺផ្ទុកទៅដោយមេរោគផងដែរ
អញ្ចឹងយើងអត់ត្រូវញុាំ ឬក៏អត់ត្រូវលេបវាទេ ប្រសិនបើយើងលេបវា អាចធ្វើឲ្យយើងឆ្លងមេរោគបាន
អញ្ចឹងយើងត្រូវញើសវាចោល ញើសវាចេញ ហើយយើងត្រូវញើសដាក់នៅក្នុងបន្ទប់ទឹក
ឬក៏ញើសដាក់នៅក្រដាសជូតមាត់ ហើយយកបោះចោលទៅក្នុងធុងសំរាម
ដែលយើងមិនត្រូវញើសសំបោរពាសវាលពាសកាលនោះទេ វាអាចធ្វើឲ្យឆ្លងជំងឺទៅអ្នកដទៃបាន។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ ក្មេងប្រុសម្នាក់នោះ
គាត់ក៏ចាប់ផ្ដើមមានអារម្មណ៍ថាក្ដៅខ្លួន អញ្ចឹងយើងឃើញនៅក្នុងរូបភាពនេះ គឺមានទែម៉ូម៉ែត្រមួយ
គឺគាត់កំពុងតែគិតអំពីទែម៉ូម៉ែត្រដែលគាត់កំពុងតែឡើងកម្ដៅ អញ្ចឹងបានន័យថាក្មេងប្រុសម្នាក់នេះ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក្ដៅខ្លួនខ្លាំង ហើយក្បាលរបស់គាត់ក៏ឈឺតិចៗផងដែរ
អញ្ចឹងគាត់យកដៃរបស់គាត់ស្ទាបក្បាលរបស់គាត់ ដែលក្បាលរបស់គាត់កំពុងតែឡើងកម្ដៅ
អញ្ចឹងជាទូទៅជំងឺផ្ដាសាយ នៅពេលដែលយើងឆ្លងជំងឺផ្ដាសាយ វាធ្វើឲ្យយើងក្ដៅខ្លួន ឈឺក្បាល
ហៀរសំបោរ និងកណ្ដាស់ ដែលធ្វើឲ្យយើងពិបាកនៅក្នុងខ្លួនមែនទែន គឺពិបាកនៅក្នុងការរស់នៅ
ដោយសារតែជំងឺផ្ដាសាយវាធ្វើឲ្យយើងក្ដៅខ្លួនខ្លាំង ហើយឈឺក្បាលនិងមានអារម្មណ៍ថាហៀរសំបោរ
មានអារម្មណ៍ថាកណ្ដាស់ផងដែរ អញ្ចឹងនៅក្នុងរូបភាពនេះគឺក្មេងប្រុសម្នាក់នោះ គាត់កំពុងតែក្ដៅខ្លួន
អញ្ចឹងគាត់ត្រូវតែញ៉ាំថ្នាំឬក៏ទៅជួបនឹងគ្រូពេទ្យ ដើម្បីធ្វើឲ្យខ្លួនរបស់គាត់ចុះកម្ដៅវិញ។

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញថា ក្មេងប្រុសម្នាក់នោះ
គាត់ក៏ចាប់ផ្ដើមអស់កម្លាំង បានន័យថាល្ហិតល្ហៃ អស់កម្លាំងល្ហិតល្ហៃ អញ្ចឹងនៅពេលដែលយើងឈឺ
ជាទូទៅមនុស្សឈឺ គឺតែងតែអស់កម្លាំងល្ហិតល្ហៃ ដោយមិនថាជំងឺផ្ដាសាយ ឬក៏ជំងឺផ្សេងៗនោះទេ
នៅពេលដែលយើងមានជំងឺ គឺតែងតែអស់កម្លាំង អញ្ចឹងក្មេងប្រុសម្នាក់នោះគាត់ឈឺ
ដូច្នេះហើយវាធ្វើឲ្យគាត់អស់កម្លាំងយ៉ាងខ្លាំង ដែលយើងឃើញនៅក្នុងរូបភាពនេះ
គឺគាត់អង្គុយលើសាឡុងមួយ ហើយអង្គុយដោយអាការអស់កម្លាំងយ៉ាងខ្លាំង ដែលគាត់កំពុងតែឈឺ។

បន្ទាប់មកទៀតរូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញថា បន្ទាប់ពីគាត់អស់កម្លាំង
ក្មេងប្រុសម្នាក់នោះ គាត់ក៏បានយកថ្នាំមកញ៉ាំ អញ្ចឹងបានន័យថានៅផ្ទះគាត់ក៏មានថ្នាំដែរ
គឺគាត់មានថ្នាំសម្រាប់បម្រុង បម្រុងទុកថ្នាំដើម្បីញ៉ាំ នៅពេលដែលគាត់មានជំងឺផ្សេងៗ
អញ្ចឹងរូបភាពនេះ បុរសម្នាក់នោះ គាត់ក៏បានចាក់ថ្នាំម្សៅ អញ្ចឹងគាត់មានថ្នាំម្សៅ
យើងឃើញគាត់ចាក់កញ្ចប់ម្សៅ ម្សៅថ្នាំ ចូលទៅក្នុងទឹក នៅក្នុងកែវទឹកមួយ ដើម្បីញ៉ាំថ្នាំ
នៅពេលដែលគាត់មានជំងឺផ្ដាសាយ យើងឃើញថាទឹកនោះគឺជាទឹកក្ដៅអ៊ុនៗ
អញ្ចឹងជាទូទៅយើងញ៉ាំទឹក យើងញ៉ាំថ្នាំជាមួយនឹងទឹកក្ដៅ
យើងអត់ញ៉ាំទឹកថ្នាំជាមួយនឹងទឹកកកនោះទេ ព្រោះវាធ្វើឲ្យបាត់បង់ប្រសិទ្ធិភាពថ្នាំ
អញ្ចឹងយើងញ៉ាំទឹក[ជាមួយ] យើងញ៉ាំថ្នាំជាមួយនឹងទឹកក្ដៅ ដែលគាត់ញ៉ាំថ្នាំនេះ
គឺជាញ៉ាំថ្នាំប្រភេទម្សៅ ថ្នាំគឺមានពីរប្រភេទ គឺប្រភេទម្សៅនិងប្រភេទគ្រាប់ ដែលជាទូទៅមនុស្សធំ
គឺយើងញ៉ាំប្រភេទគ្រាប់ ហើយទារកឬក៏កុមារ យើងញ៉ាំជាប្រភេទម្សៅ ក៏ប៉ុន្តែពេលខ្លះ
មនុស្សធំក៏អាចញ៉ាំជាថ្នាំប្រភេទម្សៅបានដែរ ព្រោះថាអាស្រ័យទៅលើស្ថានភាពជំងឺ
ប្រសិនបើជំងឺធ្ងន់ធ្ងរ យើងអាចឲ្យញ៉ាំជាប្រភេទម្សៅ ដើម្បីឲ្យអ្នកជំងឺងាយស្រួលញ៉ាំ
អញ្ចឹងនៅក្នុងរូបភាពនេះ ក្មេងប្រុសម្នាក់នោះ គាត់ចង់ញ៉ាំជាប្រភេទម្សៅ។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា បន្ទាប់ពីញ៉ាំថ្នាំជាប្រភេទម្សៅរួចរាល់ហើយ ក្មេងប្រុសម្នាក់នោះ គាត់ក៏បានញ៉ាំថ្នាំនោះ ជាប្រភេទគ្រាប់ម្តងទៀត អញ្ចឹងបានន័យថាគាត់ញ៉ាំទាំងពីរ គឺគាត់ញ៉ាំទាំងម្សៅ គាត់ញ៉ាំទាំងគ្រាប់ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញថា គាត់ដាក់ថ្នាំចំនួនបីគ្រាប់នៅលើបាតដៃរបស់គាត់ ជាទូទៅថ្នាំគ្រាប់គឺរៀងពិបាកលេបជាងថ្នាំម្សៅបន្តិច ព្រោះថាវាវឹង អញ្ចឹងយើងត្រូវដាក់ចូលក្នុងមាត់ហើយយើងលេបចូលទៅក្នុងពោះរបស់យើងដោយប្រើទឹក អញ្ចឹងថ្នាំជាទូទៅគឺមានរសជាតិល្វីង ដូច្នេះយើងអត់ងាយស្រួលក្នុងការញ៉ាំនោះទេ គឺវាមានរសជាតិល្វីងខ្លាំង ហើយប៉ុន្តែថ្នាំល្វីងគឺអាចធ្វើឲ្យយើងឆាប់ជាសះស្បើយ ដូច្នេះនៅពេលដែលយើងឈឺ ទោះបីជាយើងឈឺបន្តិចបន្តួច ក៏យើងត្រូវតែញ៉ាំថ្នាំផងដែរ ដើម្បីឲ្យឆាប់ជា។

បន្ទាប់មកទៀតនៅក្នុងរូបភាពទី ១០ នៅក្នុងរូបភាពទី ១០ យើងឃើញថា នៅពេលដែលគាត់កើតជំងឺផ្តាសាយ គឺវាធ្វើឲ្យគាត់អស់កម្លាំង អញ្ចឹងគាត់ក៏បានគេង អញ្ចឹងគាត់អស់កម្លាំង ហើយគាត់ងងុយគេងនៅក្នុងពេលថ្ងៃ អញ្ចឹងគាត់គេងទាំងថ្ងៃតែម្តង នៅក្នុងរូបភាពទី ១០ នេះ នៅក្នុងរូបភាពខាងឆ្វេង រូបភាពទី ១០ ខាងឆ្វេង គឺយើងឃើញគាត់កំពុងតែគេង ដែលយើងឃើញនៅខាងក្រៅបង្អួចរបស់គាត់ គឺព្រះអាទិត្យកំពុងតែរះ អញ្ចឹងបានន័យថាជាពេលថ្ងៃ អញ្ចឹងគាត់គេងពេលថ្ងៃ គាត់គេងពេលថ្ងៃ អញ្ចឹងគាត់គេងនៅពេលថ្ងៃដោយគាត់គេងដណ្តប់ភួយ និងគេងលើខ្នើយកើយរបស់គាត់ ដែលនៅលើគ្រែរបស់គាត់ក្បែរបង្អួច ទោះជាពេលថ្ងៃក៏ដោយក៏គាត់ដណ្តប់ភួយដែរ ព្រោះថាផ្តាសាយធ្វើឲ្យយើងក្តៅខ្លួន និងពេលខ្លះធ្វើឲ្យយើងមានអារម្មណ៍ថារងា យើងហៅថាគ្រុន អញ្ចឹងជំងឺផ្តាសាយ យើងអាច នៅពេលដែលយើងរងា នៅពេលដែលយើងមានអារម្មណ៍ថារងា យើងហៅថាគ្រុនផ្តាសាយ អញ្ចឹងរូបភាពនេះគឺគាត់គ្រុនផ្តាសាយដោយគាត់រងា អញ្ចឹងទោះបីជាពេលថ្ងៃ ក៏គាត់គេងដណ្តប់ភួយផងដែរ។

បន្ទាប់មករូបភាពទី ១០ ដែលនៅខាងស្តាំ រូបភាពទី ១០ ដែលនៅខាងស្តាំគឺជាពេលល្ងាច អញ្ចឹងបានន័យថាគាត់គេងតាំងពីថ្ងៃរហូតដល់ល្ងាច ព្រោះនៅក្នុងរូបភាពទី ១០ យើងឃើញថា ព្រះអាទិត្យចាប់ផ្តើមលិចនៅខាងក្រោយភ្នំ អញ្ចឹងពេលថ្ងៃគឺមានព្រះអាទិត្យរះ ដល់ពេលពេលល្ងាចគឺព្រះអាទិត្យលិច អញ្ចឹងនៅពេលដែលព្រះអាទិត្យចាប់ផ្តើមលិច នឹងមានព្រះចន្ទរះចេញមកម្តង ប៉ុន្តែនៅក្នុងរូបភាពនេះ គឺអត់ទាន់យប់នៅឡើយទេ គឺបានន័យថាពេលរសៀលឬក៏ពេលល្ងាច ប្រហែលជាម៉ោង ៤ ឬម៉ោង ៥ ល្ងាច ដែលព្រះអាទិត្យទើបតែចាប់ផ្តើមលិច អញ្ចឹងនៅក្នុងរូបភាពនេះ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងឃើញព្រះអាទិត្យក៏កំពុងតែលិចចុះទៅខាងក្រោម ហើយក្មេងប្រុសម្នាក់នោះ
គាត់ក៏អត់ទាន់ភ្ញាក់ពីគេងនោះទេ ដោយសារតែគាត់មានអារម្មណ៍ថាអស់កម្លាំង
គាត់មានអារម្មណ៍ថាអស់កម្លាំង ព្រោះតែគាត់កើតជំងឺផ្ដាសាយ។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ យើងឃើញក្មេងប្រុសម្នាក់នោះ គាត់ក៏ចាប់ផ្ដើមក្អក
អញ្ចឹងជំងឺផ្ដាសាយ ជាទូទៅប្រសិនបើយើងកើតជំងឺផ្ដាសាយ គឺវាធ្វើឲ្យយើងក្អក
វាធ្វើឲ្យយើងកណ្ដាស់ជាដើម អញ្ចឹងក្មេងប្រុសម្នាក់នោះ គាត់ឈឺប្រហែលជាធ្ងន់ធ្ងរដែរ
ប្រហែលជាធ្ងន់ធ្ងរ ព្រោះថាគាត់ទាំងកណ្ដាស់ ទាំងផ្ដាសាយ ទាំងក្អក ទាំងក្ដៅខ្លួន
គឺគាត់មានទាំងអស់ អញ្ចឹងបានន័យថា[ជំងឺ] រោគ សញ្ញានៃជំងឺផ្ដាសាយ គឺចេញមកទាំងអស់
បានន័យថាគាត់ឈឺនេះធ្ងន់ធ្ងរដែរ ដែលយើងឃើញនៅក្នុងរូបភាពនេះ គឺគាត់កំពុងតែក្អក
អញ្ចឹងក្អកគឺយើងរមាស់ក នៅពេលដែលយើងរមាស់ក វាធ្វើឲ្យយើងក្អក អញ្ចឹងនៅក្នុងរូបភាពនេះ
យើងឃើញថា ក្មេងប្រុសម្នាក់នោះ គាត់កំពុងតែបិទភ្នែកដើម្បីក្អក
ហើយយកដៃរបស់គាត់ខ្ទប់មាត់របស់គាត់ ឬដៃរបស់គាត់ក្ដាប់ អញ្ចឹងគាត់ក្ដាប់ដៃរបស់គាត់
ដើម្បីយកមកខ្ទប់មាត់របស់គាត់ដើម្បីក្អក អញ្ចឹងនៅពេលដែលយើងផ្ដាសាយ យើងគួរតែពាក់ម៉ាស
ឬក៏យកអ្វីមកបាំងមាត់របស់យើង ឬក៏ក្រណាត់ នៅពេលដែលយើងក្អក
ឬក៏ពេលដែលយើងកណ្ដាស់ ព្រោះថាប្រសិនបើយើងអត់យកក្រណាត់
ឬក៏អត់យកម៉ាសមកបាំងមាត់របស់យើងទេ នៅពេលដែលយើងកណ្ដាស់
ឬក៏នៅពេលដែលយើងក្អក វាអាចធ្វើឲ្យយើងចម្លងជំងឺផ្ដាសាយទៅដល់អ្នកដទៃបាន
អញ្ចឹងនៅពេលដែលយើងមានជំងឺផ្ដាសាយ យើងត្រូវតែការពារអ្នកដទៃផងដែរ
ដោយយើងត្រូវតែយកក្រណាត់ឬក៏ពាក់ម៉ាស ដើម្បីកុំឲ្យឆ្លងទៅអ្នកដទៃ។

បន្ទាប់មកទៀតរូបភាពទី ១២ រូបភាពទី ១២ ក្មេងប្រុសម្នាក់នោះ គាត់ក៏មានអាការឈឺក្បាលទៀត
អញ្ចឹងបានន័យថាគាត់ឈឺ ឈឺជំងឺផ្ដាសាយ គឺធ្វើឲ្យគាត់ពិបាកនៅក្នុងការរស់នៅណាស់
ដោយសារតែយើងឃើញនៅក្នុងរូបភាពនេះ គឺក្មេងប្រុសម្នាក់នោះ គឺគាត់ធ្វើមុខជូរ
ដោយសារតែគាត់ឈឺក្បាល យើងឃើញគាត់មានមាត់ ធ្វើមាត់ស្រួច
ហើយយកដៃខ្ទប់ក្បាលរបស់គាត់ ឬក៏អង្អែលក្បាលរបស់គាត់
ដោយសារតែគាត់កំពុងតែមានអារម្មណ៍ឈឺក្បាលយ៉ាងខ្លាំង ព្រោះថាគាត់មានជំងឺផ្ដាសាយ
អញ្ចឹងយើងឃើញគាត់ធ្វើភ្នែក ធ្វើភ្នែកតូចៗ បើកភ្នែកតូចៗ គឺព្រោះតែគាត់ឈឺក្បាលរបស់គាត់ខ្លាំង
អញ្ចឹងហើយគាត់បើកភ្នែកតូចៗ ហើយយកដៃអង្អែលក្បាលរបស់គាត់
អញ្ចឹងជំងឺផ្ដាសាយក៏អាចធ្វើឲ្យយើងឈឺក្បាលផងដែរ។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញថា ក្មេងប្រុសម្នាក់នោះ គាត់ក៏បានគេងម្តងទៀត ដោយសារតែគាត់អស់កម្លាំងនៅពេលដែលគាត់មានជំងឺផ្តាសាយ អញ្ចឹងជាទូទៅនៅពេលដែលយើងកើតជំងឺផ្តាសាយ វាធ្វើឲ្យយើងឈឺក្បាលនិងងងុយគេង ហើយពេលខ្លះ នៅពេលដែលយើងញ៉ាំថ្នាំផ្តាសាយ ឬក៏នៅពេលដែលយើងលេបថ្នាំផ្តាសាយ ថ្នាំផ្តាសាយគឺមានសារជាតិធ្វើឲ្យយើងងងុយគេង ដូច្នេះហើយនៅពេលដែលយើងផ្តាសាយ គឺយើងញ៉ាំថ្នាំផ្តាសាយ វាអាចធ្វើឲ្យយើងងងុយគេងខ្លាំង អញ្ចឹងនៅក្នុងរូបភាពនេះ ក្មេងប្រុសម្នាក់នោះ គាត់ក៏បានគេងនៅលើសាឡុងរបស់គាត់ ដោយគាត់អត់បានចូលទៅក្នុងបន្ទប់គេងទេ អញ្ចឹងគាត់អស់កម្លាំងខ្លាំង ដូច្នេះហើយគាត់ក៏បានគេងនៅលើសាឡុងរបស់គាត់ ដែលគាត់កំពុងតែអង្គុយមើលទូរទស្សន៍ អញ្ចឹងនៅខាងមុខសាឡុង គឺយើងឃើញមានទូរទស្សន៍មួយ ដែលកំពុង គាត់អង្គុយមើលទូរទស្សន៍ ហើយអស់កម្លាំង គាត់ក៏បានគេងនៅលើសាឡុងនោះ ដែលសាឡុងរបស់គាត់គឺយើងឃើញមានពណ៌ខៀវ អញ្ចឹងគាត់គេងលើសាឡុង ដោយគេងបញ្ឈរជង្គង់ តែដៃរបស់គាត់ទាំងពីរ គឺដាក់នៅលើសាឡុង ហើយក្បាលរបស់គាត់ គឺកើយទៅលើបង្កាន់ដៃសាឡុង អញ្ចឹងរូបភាពនេះ គឺគាត់កំពុងតែគេងនៅលើសាឡុង ដោយសារតែគាត់អស់កម្លាំងខ្លាំងពេក។

បន្ទាប់មកទៀតនៅក្នុងរូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ យើងឃើញថា បន្ទាប់ពីគាត់ឈឺអស់ជាច្រើនថ្ងៃ យើងឃើញនៅក្នុងរូបភាពនេះគឺជារូបភាពប្រតិទិន អញ្ចឹងប្រតិទិនបង្ហាញថ្ងៃ ជាច្រើនថ្ងៃ បានន័យថា ១២ ១៣ ១៤ ឬក៏ថ្ងៃទី ១២ ថ្ងៃទី ១៣ ថ្ងៃទី ១៤ អញ្ចឹងពេលវេលាគឺចេះតែកន្លងផុត អញ្ចឹងបានន័យថាពេលវេលាកន្លងផុតទៅជាច្រើនថ្ងៃ ដែលយើងឃើញថា នៅក្នុងមួយខែ គឺមាន នៅក្នុងមួយឆ្នាំ គឺមាន ១២ ខែ ហើយខែនីមួយៗ មានដូចជាខែទី ១ គឺខែមករា ទី ២ ខែកុម្ភៈ ទី ៣ ខែមីនា ទី ៤ ខែមេសា ទី ៥ ខែមិថុនា ខែឧសភា ទី ៦ ខែមិថុនា ទី ៧ ខែកក្កដា ទី ៨ ខែសីហា ខែទី ៩ គឺខែកញ្ញា ខែ ១០ គឺខែតុលា ខែ ១១ ខែវិច្ឆិកា និងខែ ១២ គឺខែធ្នូ អញ្ចឹងមួយឆ្នាំមាន ១២ ខែ ក៏ប៉ុន្តែនៅក្នុងការមានជំងឺផ្តាសាយ គឺអត់យូរទេ បានន័យថាត្រឹមតែមួយសប្តាហ៍ ឬក៏មួយអាទិត្យតែប៉ុណ្ណោះ អញ្ចឹងត្រឹមតែមួយអាទិត្យ គឺយើងអាចជាពីជំងឺផ្តាសាយហើយ ដូច្នេះហើយយើងឃើញថានៅក្នុងរូបភាពនេះ គឺពេលវេលារំលងទៅប្រហែលជាមួយសប្តាហ៍ ដែលមួយសប្តាហ៍គឺមាន ៧ ថ្ងៃ ដែលយើងឃើញថាថ្ងៃនៅក្នុងមួយសប្តាហ៍គឺមាន ៧ មានដូចជាថ្ងៃចន្ទ ថ្ងៃអង្គារ ថ្ងៃពុធ ថ្ងៃព្រហស្បតិ៍ ថ្ងៃសុក្រ ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ អញ្ចឹងមានចំនួន ៧ ថ្ងៃ ហើយជំងឺផ្តាសាយ គឺជាទូទៅគឺតែងតែកើតមានចំនួនតែ ៧ ថ្ងៃប៉ុណ្ណោះ យើងនឹងអាចជាសះស្បើយបាន

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងនៅក្នុងរូបភាពទី ១៤ នេះ បាននន័យថាកន្លងទៅជាច្រើនថ្ងៃ កន្លងទៅច្រើនថ្ងៃ បាននន័យថាក្មេងប្រុសនោះ គាត់ឈឺច្រើនថ្ងៃ។

បន្ទាប់មកទៀតរូបភាពទី ១៥ អញ្ចឹងបន្ទាប់ពីកន្លងទៅច្រើនថ្ងៃមក ក្មេងប្រុសម្នាក់នោះ គាត់ក៏បានជាសះស្បើយពីជំងឺផ្តាសាយ អញ្ចឹងថ្ងៃនេះគឺគាត់មានសុខភាពល្អឡើងវិញហើយ បាននន័យថាគាត់ជាពីជំងឺផ្តាសាយ ដូច្នេះគាត់ក៏បានដើរលេងនៅខាងក្រៅ អញ្ចឹងក្មេងប្រុសម្នាក់នោះ គាត់ក៏បានចេញមកខាងក្រៅ ដែលយើងឃើញថាក្មេងប្រុសម្នាក់នោះ គឺគាត់ជាអ្នករស់នៅជនបទ អញ្ចឹងបាននន័យថាគឺគាត់ នៅខាងក្រោយគឺយើងឃើញមានផ្ទះតូចៗជាច្រើន ហើយមានដើមឈើពណ៌បៃតងដុះនៅតាមជិតផ្ទះជាច្រើន អញ្ចឹងបាននន័យថានៅទីជនបទ ព្រោះថានៅជនបទសម្បូរដើមឈើ ចំណែកនៅទីក្រុងគឺអត់សូវសម្បូរដើមឈើទេ ក៏ប៉ុន្តែនៅទីក្រុងគឺគាត់សម្បូរអគារខ្ពស់ៗជាច្រើន អគារពាណិជ្ជកម្ម ប៉ុន្តែនៅតាមទីជនបទ ឬក៏តាមស្រុកស្រែនានា គឺសម្បូរទៅដោយដើមឈើ ប៉ុន្តែអត់សូវមានអគារខ្ពស់ៗទេ អញ្ចឹងក្មេងប្រុសម្នាក់នេះ គាត់ក៏រស់នៅជនបទ ហើយនៅពេលដែលគាត់ឈឺផ្តាសាយបានចំនួនប្រហែលមួយសប្តាហ៍ គាត់ក៏បានជាសះស្បើយ អញ្ចឹងគាត់មានអារម្មណ៍ថារីករាយ ដោយសារតែគាត់ជាសះស្បើយពីជំងឺផ្តាសាយ ដូច្នេះគាត់ក៏បានចេញមកដើរលេងខាងក្រៅ ដើម្បីស្រូបយកខ្យល់អាកាស ហើយនិងហាត់ប្រាណ ដើម្បីឲ្យគាត់មានសុខភាពល្អ លែងមានជំងឺផ្តាសាយទៀត។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.